លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ក្រោយពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា១០.-**

១០.១. ក្រុមប្រឹក្សាភិបាលនៃ **ម.ព.ក.ស.** ត្រូវធ្វើការប្រជុំយ៉ាងតិច ៣(បី)ខែម្តង តាមគំនិតផ្តួចផ្តើមនិងការអញ្ជើញរបស់ប្រធាន ឬ តាមការស្នើរបស់សមាជិកចំនួន ២/៣ (ពីរភាគបី)ឡើងទៅ ឬតាមការស្នើសុំរបស់នាយក

**ម.ព.ក.ស.**។ ក្នុងករណីមានធុរៈ ប្រធានត្រូវផ្ទេរសិទ្ធិជូនសមាជិកណាម្នាក់ក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាលដើម្បីដឹកនាំការប្រជុំ។ ប្រធានអង្គប្រជុំត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ ១ (មួយ)រូប ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាលតែគ្មានសិទ្ធិបោះឆ្នោតទេ ។

របៀបវារៈព្រមទាំងឯកសារទាំងឡាយ ត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាលនិងគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធដែលមានចែងក្នុងអនុក្រឹត្យនេះយ៉ាងតិច ១០(ដប់) ថ្ងៃមុនថ្ងៃប្រជុំ។

**១០.២.** ការប្រជុំនៃក្រុមប្រឹក្សាភិបាលអាចនឹងយកជាការបាន លុះត្រាតែមានសមាជិកចំនួនលើសពី ៥០ (ហាសិប) ភាគរយនៃសមាជិកទាំងអស់។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឱ្យមកប្រជុំជំនួសបានឡើយ។ ប្រសិនបើកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀតយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះមិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈនៃការអញ្ជើញប្រជុំលើកមុន។ សមាជិកវត្តមាន ត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំចាត់ទុកជាឧត្តមានុភាព ។

**១០.៣.** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ តម្កល់ទុកនៅទីស្នាក់ការរបស់ **ម.ព.ក.ស.** និងត្រូវបានចុះហត្ថលេខាដោយប្រធានអង្គប្រជុំនិងលេខាធិការអង្គប្រជុំ ។ កំណត់ហេតុនេះត្រូវបង្ហាញនូវអត្ថន័យនៃការពិភាក្សាឱ្យបានច្បាស់លាស់ និងត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួងពាក់ព័ន្ធយ៉ាងយូរ ១០ (ដប់) ថ្ងៃ ក្រោយពេលប្រជុំ។

**១០.៤.** **ម.ព.ក.ស.**ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនូវឯកសារដូចតទៅ ÷

- កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍរបស់ **ម.ព.ក.ស.**
- គម្រោងថវិកាប្រចាំឆ្នាំ
- របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ។

**១០.៥.** ឯកសារទាំងនេះត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួលក្នុងរយៈពេលមិនហួសពី ១៥(ដប់ប្រាំ) ថ្ងៃ។

## ផ្នែកទី២
## អង្គការប្រតិបត្តិនៃមន្ទីរពេទ្យ

**មាត្រា១១.-**

**ម.ព.ក.ស.**ត្រូវគ្រប់គ្រងដោយនាយកមន្ទីរពេទ្យមួយរូប ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ នាយកមន្ទីរពេទ្យរូបនេះមានតួនាទីជានាយកប្រតិបត្តិ។

**មាត្រា១២.-**

**១២.១.** នាយកនៃ **ម.ព.ក.ស.** មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រង និងអនុវត្តការងារដែលមានចែងក្នុងអនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល។

នាយកនៃ **ម.ព.ក.ស.**មានភារកិច្ច÷

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឱ្យដំណើរការនូវគោលនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាភិបាលនេះ
- រៀបចំថវិកាប្រចាំឆ្នាំសម្រាប់ **ម.ព.ក.ស.** ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេច
- ធ្វើរបាយការណ៍ការងារគ្រប់គ្រងប្រចាំឆ្នាំ ត្រួតពិនិត្យលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យ
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ **ម.ព.ក.ស.** ក្នុងកម្រិតក្របខណ្ឌចំនួនបុគ្គលិក ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធានការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់ **ម.ព.ក.ស.** ដែលកំណត់ដោយក្រុមប្រឹក្សាភិបាលស្តីពីការបែងចែកសិទ្ធិអំណាចនិងទៅតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិដទៃទៀត។

**១២.២.** នាយកនៃ **ម.ព.ក.ស.**ជាតំណាងរបស់មន្ទីរពេទ្យ ក្នុងទំនាក់ទំនងជាមួយតតិយជន។

**១២.៣.** នាយកនៃ **ម.ព.ក.ស.**ត្រូវស្នើទៅក្រសួងសុខាភិបាល សុំតែងតាំងនាយករងមួយរូប ឬច្រើនរូបដែលជាជំនួយការតាមការចាំបាច់ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល។ នាយក និងនាយករង ត្រូវមានចំណេះដឹងលើផ្នែកគ្រប់គ្រង។

## ផ្នែកទី៣
## បុគ្គលិករបស់ ម.ព.ក.ស.

**មាត្រា១៣.-**

**១៣.១.** បុគ្គលិកអចិន្ត្រៃយ៍របស់ **ម.ព.ក.ស.**រួមមានមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈមកពីក្រសួងសុខាភិបាលឬមកពីក្រសួងស្ថាប័នដទៃទៀត។ មន្ត្រីទាំងឡាយនេះត្រូវបានរក្សាទុកក្របខណ្ឌ ប្រាក់បៀវត្ស និង ប្រាក់កម្រៃផ្សេងៗ ដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន។

**១៣.២.** មន្ទីរពេទ្យអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ជំនួយការ និងបុគ្គលិកអណ្តែត។ បុគ្គលិកទាំងនេះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងនិងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ស្តីពីការងារ។

**១៣.៣.** បុគ្គលិក **ម.ព.ក.ស.**ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីការគ្រប់គ្រងបុគ្គលិកដែលបានសម្រេចដោយក្រុមប្រឹក្សាភិបាល។ ចំពោះមន្ត្រីរាជការនៃមុខងារសាធារណៈ បទបញ្ជាស្តីពីបុគ្គលិកនេះមិនត្រូវផ្ទុយពី

បទប្បញ្ញត្តិទាំងឡាយនៃច្បាប់និងអត្ថបទពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការឡើយ ។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កម្រៃលើកទឹកចិត្តចំពោះបុគ្គលិកព្រមទាំងបែបបទនៃការទូទាត់ផង ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង។

## ជំពូកទី៤
## ទ្រព្យសម្បត្តិនៃមន្ទីរពេទ្យ

**មាត្រា១៤.-**

**១៤.១. ម.ព.ក.ស.** ទទួលដើមទុនដំបូងពីរដ្ឋជាដីធ្លីនិងអចលនវត្ថុដែលមានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធតាមបញ្ជីសារពើភណ្ឌចុងក្រោយ ដែលផ្ទៃដីមានប្រមាណ ២៦ ៥៨៨ (ម្ភៃប្រាំមួយពាន់ប្រាំរយប៉ែតសិបប្រាំបី) ម៉ែត្រក្រឡា ក្នុងនោះមានអាសយដ្ឋានដីឡូតិ៍លេខ ១៨៨ ផ្លូវ ២៧១ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**១៤.២. ម.ព.ក.ស.** អាចទិញ ប្តូរ ឬលក់ចលនទ្រព្យ អចលនទ្រព្យចាំបាច់សម្រាប់ដំណើរការរបស់មន្ទីរពេទ្យ ដោយមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ និងស្របតាមច្បាប់ជាធរមាន។

## ជំពូកទី៥
## ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យរបស់ ម.ព.ក.ស.

**មាត្រា១៥.-**

ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យនៃ **ម.ព.ក.ស.** ត្រូវប្រព្រឹត្តស្របតាមគោលការណ៍នៃគណនេយ្យសាធារណៈ ដូចមានចែងនៅក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ។

**មាត្រា១៦.-**

**១៦.១.** នាយកនៃ **ម.ព.ក.ស.** ជាអាណាប័កដើមខ្សែរបស់មន្ទីរពេទ្យហើយត្រូវមានភារកិច្ច ៖

- ពិនិត្យប្រាក់និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់និងចេញបញ្ជាចំណាយ។

**១៦.២.** អាណាប័កដើមខ្សែ អាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិឬអាចបង្កើតនូវរជ្ជទេយ្យចំណូលឬបុរេប្រទានបានដោយមានការព្រមព្រៀងពីគណនេយ្យករ **ម.ព.ក.ស.**។

**មាត្រា១៧.-**

**១៧.១.** ការគ្រប់គ្រងហិរញ្ញវត្ថុនិងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ **ម.ព.ក.ស.** ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។ គណនេយ្យករត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ។ គណនេយ្យករនេះត្រូវ

ទទួលខុសត្រូវចំពោះមុខនាយក **ម.ព.ក.ស.** និងត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់ តែឥតមានសំឡេងឆ្នោតឡើយ។

**១៧.២.** គណនេយ្យករមានភារកិច្ច÷

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- ថែរក្សានិងចាត់ចែងប្រើប្រាស់នូវមូលនិធិនិងធនធានរបស់ **ម.ព.ក.ស.**
- ថែរក្សាលិខិតយុត្តិការនិងកាន់កាប់បញ្ជីគណនេយ្យ។

**១៧.៣.** គណនេយ្យករអាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុការរបស់ខ្លួន។

**មាត្រា១៨.-**

**១៨.១.** ប្រភពធនធានរបស់ **ម.ព.ក.ស.** រួមមាន÷

- ធនធានដំបូងរបស់រដ្ឋផ្តល់ដល់ **ម.ព.ក.ស.** នៅពេលផ្តើមបង្កើតដំបូង
- ឧបត្ថម្ភធនសម្រាប់ដំណើរការនិងឧបត្ថម្ភធនជាមូលធន ដែលមានចែងក្នុងថវិកាជាតិ
- អំណោយ ជំនួយ និងអច្ច័យទានដែល **ម.ព.ក.ស.** បានទទួល
- ប្រាក់ខ្ចីដោយផ្ទាល់និងប្រាក់ដែលរដ្ឋខ្ចីបុលឱ្យ **ម.ព.ក.ស.**
- ផលការងារនិងកម្រៃនៃការផ្តល់សេវាផ្សេងៗដោយ **ម.ព.ក.ស.**
- កម្រៃនៃទ្រព្យរបស់ **ម.ព.ក.ស.** និងចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល
- កម្រៃនៃទ្រព្យសម្បត្តិដែលបានប្រគល់ឱ្យ **ម.ព.ក.ស.**។

**១៨.២.** ចំណូលចំណាយជាប្រចាំព្រមទាំងមូលធនរបស់ **ម.ព.ក.ស.** ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់ **ម.ព.ក.ស.**។ ក្រុមប្រឹក្សាភិបាលរបស់ **ម.ព.ក.ស.** ត្រូវកំណត់អំពីបែបបទនៃការរៀបចំចាត់ចែង និងអនុវត្តថវិកា។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលទាក់ទងដល់ទម្រង់បែបបទនៃការរៀបចំចាត់ចែង និងអនុវត្តថវិកាត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**១៨.៣.** ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ **ម.ព.ក.ស.** ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវធ្វើការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្នុងឆ្នាំនីមួយៗ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹងរវាងចំណូល និងចំណាយ។

**១៨.៤.** អនុលោមតាមមាត្រា ១៣ ខាងលើនេះ ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗនៃមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈដែលមកបម្រើការងារក្នុង **ម.ព.ក.ស.** ជាបន្ទុកនៃថវិការដ្ឋ។

**១៨.៥.** ប្រាក់ឧបត្ថម្ភរបស់រដ្ឋដែលបានគ្រោងទុកក្នុងថវិកាជាតិ ដើម្បីផ្តល់ឱ្យ **ម.ព.ក.ស.** ត្រូវសំដៅជា ពិសេសលើចំណាយថ្លៃទឹកនិងថ្លៃភ្លើង។

**១៨.៦.** សោហ៊ុយវិភាគនិងសោហ៊ុយដំណើរការ សម្រាប់ស្រាវជ្រាវវិភាគ សម្រាប់ពេលមានភាពអាសន្ន ត្រូវចែងក្នុងកិច្ចសន្យាមួយរវាងរដ្ឋ និង **ម.ព.ក.ស.** ដែលមានបញ្ជាក់ចំណែកដែលម្ខាងៗត្រូវរ៉ាប់រង។

**មាត្រា១៩.-**

**១៩.១.** ការងារគណនេយ្យរបស់ **ម.ព.ក.ស.** រួមមាន ÷

- គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគ ដែលចែងអំពីប្រតិបត្តិការថវិការតនាគារនិងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន
- គណនេយ្យ អសង្ហារិម រូបធាតុ និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគប្រសិនបើជាការចាំបាច់។

គណនេយ្យរបស់ **ម.ព.ក.ស.** ត្រូវ ÷

- ស្របតាមវិធានដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គោរពតាមប្លង់គណនេយ្យរបស់ **ម.ព.ក.ស.** ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

ប្លង់គណនេយ្យនេះត្រូវបានយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**១៩.២.** របាយការណ៍ស្តីពីការគ្រប់គ្រង និង គណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ **ម.ព.ក.ស.** ត្រូវរៀបចំដោយគណនេយ្យករ និង អាណាប័កដើមខ្សែដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣ (បី)ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ។

**មាត្រា២០.-**

មូលនិធិរបស់ **ម.ព.ក.ស.** គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនីមួយនៅរតនាគារជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិ ដែលត្រូវមានការយល់ព្រមដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៦
## របបសារពើពន្ធនៃ ម.ព.ក.ស.

**មាត្រា២១.-**

លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់ **ម.ព.ក.ស.** ត្រូវស្ថិតនៅក្រោមនីតិរបបចំពោះរបបសារពើពន្ធ។

## ជំពូកទី៧
## លទ្ធកម្មរបស់ ម.ព.ក.ស.

**មាត្រា២២.-**

ការសម្រេច ការអនុវត្តនិងការត្រួតពិនិត្យលើលទ្ធកម្មរបស់ **ម.ព.ក.ស.** ត្រូវគ្រប់គ្រងតាមច្បាប់និងបទបញ្ញាជាធរមានទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហានេះ។

## ជំពូកទី៣

## អាណាព្យាបាលភាព

### ផ្នែកទី១

### អាណាព្យាបាលបច្ចេកទេស

**មាត្រា២៣.-**

**២៣.១** ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាល នាយកនៃ **ម.ព.ក.ស.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍនិងគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីសុំការយល់ព្រម។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានរយៈពេល ១(មួយ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារ ដើម្បីរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសមានរយៈពេល ២(ពីរ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារ ដែលបានបញ្ជូនដោយនាយកនៃ **ម.ព.ក.ស.** ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

**២៣.២** លិខិតយល់ព្រមចុះហត្ថលេខា ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាលឬតំណាង ហើយត្រូវផ្ញើជូនទៅនាយកនៃ **ម.ព.ក.ស.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នាយកនៃ **ម.ព.ក.ស.** ត្រូវបញ្ជូនព័ត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសុខាភិបាលមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍឬគម្រោងថវិកាប្រចាំឆ្នាំចាត់ទុកថាបានទទួលការឯកភាព។ ប្រសិនបើរដ្ឋមន្ត្រីក្រសួងសុខាភិបាលធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ។

កម្មវិធីអភិវឌ្ឍនៃ **ម.ព.ក.ស.** និងថវិកាចំណាយជាមូលធនមិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាលពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ។

ថវិកាចំណាយជាប្រចាំអាចដាក់ឱ្យអនុវត្តត្រឹមលំនាំប្រព័ន្ធបំបែកជា ១២(ដប់ពីរ)ប៉ុណ្ណោះ នៅពេលដែលមានការជំទាស់ពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា២៤.-**

**២៤.១** រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាចមានយោបល់ជំទាស់លើឯកសារ ដែលត្រូវបានបញ្ជូនមកខ្លួនដូចមានចែងក្នុងមាត្រា ១០ ចំណុច ១០.៤ នៃអនុក្រឹត្យនេះ មានកំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍ស្តីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានរយៈពេល ១(មួយ)ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងអស់នេះ។

**២៤.២** នាយកនៃ **ម.ព.ក.ស.** ត្រូវជូនព័ត៌មានទៅដល់ក្រុមប្រឹក្សាភិបាល អំពីខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាឱ្យបានឆាប់បំផុតលើការជំទាស់របស់រដ្ឋមន្ត្រីក្រសួង

សុខាភិបាល និងវិធានការបញ្ហាបាយសម្រាប់ដោះស្រាយការជំទាស់នេះ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចពុំយកជាបានការនូវការជំទាស់ទាំងនេះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជម្រាបជាបន្ទាន់ភ្លាមនូវដំណឹងអំពីបញ្ហានេះជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា២៥.-**

**២៥.១** រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចលុបឬផ្អាកទុកនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ **ម.ព.ក.ស.** ក្នុងករណីដែលសេចក្តីសម្រេចនោះ÷

- ផ្ទុយនឹងគោលដៅរបស់មន្ទីរពេទ្យ
- ផ្ទុយនឹងច្បាប់និងបទបញ្ជា
- ធ្វើឡើងដោយអាជ្ញាធរមួយដែលពុំមានសិទ្ធិសម្រេច ឬធ្វើឡើងដោយការប្រជុំពុំស្របច្បាប់របស់ក្រុមប្រឹក្សាភិបាល។

**២៥.២** ការលុបចោលឬការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ។ ការលុបចោលឬផ្អាកទុកនូវសេចក្តីសម្រេចនេះ ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរដល់នាយកនៃ **ម.ព.ក.ស.** ហើយនាយក **ម.ព.ក.ស.** ត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាលក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា២៦.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចចាត់ឱ្យធ្វើអធិការកិច្ចឬការត្រួតពិនិត្យការងាររបស់ **ម.ព.ក.ស.** ក្នុងករណីដែលយល់ថាជាការចាំបាច់ស្របតាមលក្ខខណ្ឌនិងបែបបទដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី២
## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា២៧.-**

**២៧.១** ក្នុងរយៈពេល ១៥(ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល នាយកនៃ **ម.ព.ក.ស.** ត្រូវធ្វើរបាយការណ៍ស្តីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានរយៈពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃទទួលឯកសារដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានរយៈពេល ២(ពីរ) ខែ គិតចាប់ពីថ្ងៃទទួលឯកសារដែលបញ្ជូនមក ដោយនាយកនៃ **ម.ព.ក.ស.** ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

**២៧.២** លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬអ្នកតំណាងត្រូវផ្ញើទៅនាយកនៃ **ម.ព.ក.ស.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល។ នាយកនៃ **ម.ព.ក.ស.** ត្រូវជូនព័ត៌មាននេះដល់ក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនបានឆ្លើយតប ក្នុងរយៈពេលដូចបានកំណត់ខាងលើរបាយការណ៍ស្តីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព។ ក្នុងករណីដែល

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុត ដើម្បីរិះរកមធ្យោបាយដោះស្រាយជំទាស់ទាំងនេះ។ របាយការណ៍ស្តីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំមិនអាចត្រូវសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពុំត្រូវបានដោះស្រាយនៅឡើយនោះ។

**មាត្រា២៨.-**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលឬនាយកនៃ **ម.ព.ក.ស.** ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន ÷

- សេចក្តីសម្រេចស្តីពីការលើកលែងឥណទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់និងកិច្ចព្រមព្រៀងសម្រាប់ការធានាឬលិខិតស្រដៀងគ្នានេះ
- សេចក្តីសម្រេចស្តីពីការលក់ឬផ្ទេរសិទ្ធិអចលនទ្រព្យ។

សេចក្តីសម្រេចនេះត្រូវអនុលោមតាមនីតិវិធីច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា២៩.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ១ (មួយ)រូប ប្រចាំ **ម.ព.ក.ស.** មន្ត្រីនេះមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុននិងជាក្រោយលើ **ម.ព.ក.ស.** ស្របតាមអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាតាមក្រសួង ខេត្តក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងតាមអង្គភាពសាធារណរដ្ឋបាល។

**មាត្រា៣០.-**

៣០.១ ការគ្រប់គ្រងដោយអាណាប័កដើមខ្សែនៃ **ម.ព.ក.ស.** ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣០.២ ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់គណនេយ្យករកណ្តាលនៃរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣០.៣. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់អធិការកិច្ច ឬ ការត្រួតពិនិត្យលើ **ម.ព.ក.ស.** នៅពេលដែលយល់ថាចាំបាច់ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធនិងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៣១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមិថុនា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ដើម្បីសូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៩៦ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការប្រែក្លាយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជាគ្រឹះស្ថានសាធារណរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត សរសេរកាត់ថា **ម.ម.ខ.ស.** ត្រូវបានសម្រេចឱ្យប្រែក្លាយទៅជាគ្រឹះស្ថានសាធារណរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស របស់ក្រសួងសុខាភិបាលនិងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២.-**

**ម.ម.ខ.ស.** ជានីតិបុគ្គលនិងមានស្វ័យភាពហិរញ្ញវត្ថុ។

**ម.ម.ខ.ស.** មានអាសយដ្ឋាននៅមហាវិថីយោធពលខេមរភូមិន្ទ (ផ្លូវ២៧១) សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

ការផ្លាស់ប្តូរអាសយដ្ឋាននៅពេលអនាគតជាសមត្ថកិច្ចរបស់ **ម.ម.ខ.ស.**។

**មាត្រា៣.-**

**ម.ម.ខ.ស.** មានភារកិច្ចជាអាទិ៍ដូចតទៅ÷

- រ៉ាប់រងផ្តល់សេវាសុខាភិបាលផ្នែកព្យាបាលជំងឺទូទៅ សល្យសាស្ត្រ ទន្តសាស្ត្រ សម្ភព និងរោគស្ត្រីដល់អតិថិជនដែលបានបញ្ជូនមកឬបានសុំមកសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ ហើយផ្តល់សេវាជូនការស្នាក់នៅ តាមលទ្ធភាពរបស់មន្ទីរពេទ្យ
- ផ្តល់ការថែរក្សាព្យាបាលជំងឺស្រាលឬជំងឺធ្ងន់ទៅតាមឯកទេស
- ផ្តល់ជូនអ្នកជំងឺគ្រប់រូបនូវការពិនិត្យព្យាបាលតាមតម្រូវការនិងលទ្ធភាពរបស់សាមីអង្គភាព
- ពិគ្រោះយោបល់ និងព្យាបាលអ្នកជំងឺដោយមិនមានការរើសអើង និងតាមកម្រិតបច្ចេកទេសដូចគ្នា ប៉ុន្តែអាចផ្តល់របបស្នាក់នៅកម្រិតខុសគ្នា អាស្រ័យតាមឆន្ទៈរបស់អ្នកជំងឺឬគ្រួសារអ្នកជំងឺ ឬអាស្រ័យតាមលទ្ធភាពថវិការបស់អ្នកជំងឺ ដោយអនុលោមតាមតម្លៃសេវាកម្មរបស់មន្ទីរពេទ្យ
- សហការក្នុងផ្នែកវេជ្ជសាស្ត្រ បង្ការការពារ និងផ្តល់សេវាសម្រាប់វេជ្ជសេវាកិច្ចអាសន្ន
- ចាត់វិធានការ ដើម្បីឆ្លើយតបនឹងការសង្គ្រោះបន្ទាន់ឬរ៉ាប់រងសម្រួលឱ្យអ្នកជំងឺទៅព្យាបាលនៅមន្ទីរពេទ្យដទៃទៀត
- ផ្តល់ឱ្យអ្នកជំងឺនូវការព្យាបាលរោគ ការបង្ការរោគ និងការសម្រាលរោគតាមស្តង់ដារបច្ចេកទេស
- ចាត់ចែងឱ្យបានល្អត្រឹមត្រូវនូវការព្យាបាលបន្ទាន់ លើគ្រប់ផ្នែកនិងអាស្រ័យតាមមធ្យោបាយរបស់មន្ទីរពេទ្យ

- ចូលរួមបណ្តុះបណ្តាល និងស្រាវជ្រាវវិស័យវេជ្ជសាស្ត្រ ទន្តសាស្ត្រ និងឱសថសាស្ត្រ
- សហការក្នុងការសិក្សាផ្នែកវេជ្ជសាស្ត្រ ទន្តសាស្ត្រ និងឱសថសាស្ត្រ ព្រមទាំងជួយបណ្តុះបណ្តាលបុគ្គលិក។

## ជំពូកទី២
## ការដឹកនាំនិងការគ្រប់គ្រង
### ផ្នែកទី១
### ក្រុមប្រឹក្សាភិបាល

**មាត្រា៤.-**

**ម.ម.ខ.ស.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិទូលំទូលាយ ដើម្បីចាត់ចែងការងារក្នុងក្របខណ្ឌបទប្បញ្ញត្តិនៃអនុក្រឹត្យនេះនិងបទបញ្ជាផ្ទៃក្នុងរបស់ **ម.ម.ខ.ស.**។

**មាត្រា៥.-**

៥.១. ក្រុមប្រឹក្សាភិបាលមានសមាជិក ៧(ប្រាំពីរ)រូប ដែលមានសមាសភាពដូចតទៅ÷

| | |
|---|---|
| - តំណាងក្រសួងសុខាភិបាល | ប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - ឥស្សរជនមានចំណេះដឹងនិងបទពិសោធខាងវិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| - តំណាងសាលារាជធានីភ្នំពេញ | សមាជិក |
| - នាយកនៃ **ម.ម.ខ.ស.** | សមាជិកស្វ័យប្រវត្តិ |
| - តំណាងបុគ្គលិកនៃ **ម.ម.ខ.ស.** | សមាជិកស្វ័យប្រវត្តិ |

៥.២. តំណាងបុគ្គលិកនៃ **ម.ម.ខ.ស.** ត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិក **ម.ម.ខ.ស.** សម្រាប់អាណត្តិនីមួយៗ។

៥.៣. ប្រធាននិងសមាជិកក្រុមប្រឹក្សាភិបាល ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវបានតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣(បី) ឆ្នាំ និងអាចបន្តបានទៀត តាមសំណើរបស់ក្រសួងឬស្ថាប័នដែលជាតំណាង។

៥.៤. អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលាដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬស្ថាប័នដែលតំណាង។

**មាត្រា៦.-**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបម្រើការងារយ៉ាងតិច ៥(ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានបទពិសោធគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសុខាភិបាល សេដ្ឋកិច្ច

ឬនីតិសាស្ត្រដែលមានសញ្ជាតិខ្មែរ និងមានលិខិតថ្កោលទោសបញ្ជាក់ថាពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិមឬឧក្រិដ្ឋពីតុលាការឡើយ។

**មាត្រា៧.-**

**៧.១.** ប្រធានក្រុមប្រឹក្សាភិបាល មានតួនាទីកោះប្រជុំនិងកំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល។

**៧.២.** ប្រធានក្រុមប្រឹក្សាភិបាលអាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធលើវិស័យវិទ្យាសាស្ត្រសុខាភិបាល និងតំណាងដៃគូអភិវឌ្ឍឱ្យចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលបាន។ ឥស្សរជនទាំងនោះមានសិទ្ធិផ្តល់មតិតែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។

**មាត្រា៨.-**

ក្រុមប្រឹក្សាភិបាលមានបេសកកម្មដឹកនាំ តម្រង់ទិសដៅ និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់ **ម.ម.ខ.ស.**។ ក្នុងក្របខណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ÷

- ពិនិត្យនិងសម្រេចលើគម្រោងផែនការអភិវឌ្ឍនៃ **ម.ម.ខ.ស.** ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល
- ពិនិត្យនិងសម្រេចលើគម្រោងផែនការសកម្មភាពនៃ **ម.ម.ខ.ស.**
- ពិនិត្យនិងសម្រេចលើចំណូលនិងចំណាយប្រចាំឆ្នាំ ព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ **ម.ម.ខ.ស.**
- ពិនិត្យនិងសម្រេចលើរបាយការណ៍ស្តីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធនិងការបែងចែកភារកិច្ចជាទូទៅដល់គ្រប់ការិយាល័យ និងអង្គភាពក្រោមឱវាទ និងធ្វើការអភិវឌ្ឍតាមការចាំបាច់របស់ **ម.ម.ខ.ស.**
- កំណត់បែបបទនៃការជ្រើសរើស ការដំឡើងឋានន្តរសក្តិ ការផ្តល់លាភការដល់បុគ្គលិក **ម.ម.ខ.ស.** ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិច្បាប់ឬបទបញ្ជាផ្ទៃក្នុងដែលអនុវត្តចំពោះមន្ត្រីមុខងារសាធារណៈ
- សម្រេចលើក្របខណ្ឌចំនួនបុគ្គលិកដែលអនុញ្ញាតសម្រាប់ **ម.ម.ខ.ស.**
- សម្រេចលើកិច្ចសន្យាស្តីពីលទ្ធកម្មសាធារណៈដោយអនុវត្តតាមបទប្បញ្ញត្តិនៃលទ្ធកម្មសាធារណៈ
- កែសម្រួលបទបញ្ជាផ្ទៃក្នុងនៃ **ម.ម.ខ.ស.** ដោយមានការយល់ព្រមពីប្រធានស្ថាប័នឬក្រសួងអាណាព្យាបាលទាំងពីរ
- វាយតម្លៃតាមចន្លោះពេលទៀងទាត់លើកម្រិតលទ្ធផលសម្រេចបាន តាមគោលដៅកំណត់ដោយ **ម.ម.ខ.ស.** ហើយកំណត់នូវវិធានការកែតម្រូវ ដើម្បីអនុវត្ត។

**មាត្រា៩.-**

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ក្រោយពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា១០.-**

**១០.១.** ក្រុមប្រឹក្សាភិបាលនៃ **ម.ម.ខ.ស.** ត្រូវធ្វើការប្រជុំយ៉ាងតិច ៣(បី)ខែម្តង តាមគំនិតផ្តួចផ្តើមនិងការអញ្ជើញរបស់ប្រធានឬតាមការស្នើរបស់សមាជិកចំនួន២/៣(ពីរភាគបី)ឡើងទៅឬតាមការស្នើសុំរបស់នាយក **ម.ម.ខ.ស.**។ ក្នុងករណីមានធុរៈ ប្រធានត្រូវផ្ទេរសិទ្ធិជូនសមាជិកណាម្នាក់ក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាលដើម្បីដឹកនាំការប្រជុំ។ ប្រធានអង្គប្រជុំ ត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ ១(មួយ)រូប ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ។មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាលតែគ្មានសិទ្ធិបោះឆ្នោតទេ។ របៀបវារៈព្រមទាំងឯកសារទាំងឡាយត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាលនិងគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធដែលមានចែងក្នុងអនុក្រឹត្យនេះ យ៉ាងតិច១០ (ដប់) ថ្ងៃ មុនថ្ងៃ ប្រជុំ។

**១០.២.** ការប្រជុំនៃក្រុមប្រឹក្សាភិបាលអាចនឹងយកជាការបាន លុះត្រាតែមានសមាជិកចំនួនលើសពី ៥០ (ហាសិប)ភាគរយនៃសមាជិកទាំងអស់ ។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឱ្យមកប្រជុំជំនួសបានឡើយ ។ ប្រសិនបើកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀតយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ ក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះមិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈនៃការអញ្ជើញប្រជុំលើកមុន ។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំចាត់ទុកជាឧត្តមានុភាព ។

**១០.៣.** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ តម្កល់ទុកនៅទីស្នាក់ការរបស់ **ម.ម.ខ.ស.** និងត្រូវបានចុះហត្ថលេខាដោយប្រធានអង្គប្រជុំនិងលេខាធិការអង្គប្រជុំ។ កំណត់ហេតុនេះត្រូវបង្ហាញនូវអត្ថន័យនៃការពិភាក្សាឱ្យបានច្បាស់លាស់ និងត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួងពាក់ ព័ន្ធយ៉ាងយូរ ១០ (ដប់) ថ្ងៃ ក្រោយពេលប្រជុំ។

**១០.៤. ម.ម.ខ.ស.** ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ ÷

- កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍរបស់ **ម.ម.ខ.ស.**
- គម្រោងថវិកាប្រចាំឆ្នាំ
- របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ។

**១០.៥.** ឯកសារទាំងនេះ ត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួល ក្នុងរយៈពេលមិនហួសពី ១៥ (ដប់ប្រាំ) ថ្ងៃ។

## ផ្នែកទី២
## អង្គការប្រតិបត្តិនៃមន្ទីរពេទ្យ

**មាត្រា១១.-**

**ម.ម.ខ.ស.** ត្រូវគ្រប់គ្រងដោយនាយកមន្ទីរពេទ្យមួយរូប ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ នាយកមន្ទីរពេទ្យរូបនេះមានតួនាទីជានាយកប្រតិបត្តិ។

**មាត្រា១២.-**

**១២.១.** នាយកនៃ **ម.ម.ខ.ស.** មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រង និងអនុវត្តការងារដែលមានចែងក្នុងអនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល។

នាយកនៃ **ម.ម.ខ.ស.** មានភារកិច្ច÷

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឱ្យដំណើរការនូវគោលនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាភិបាលនេះ
- រៀបចំថវិកាប្រចាំឆ្នាំសម្រាប់ **ម.ម.ខ.ស.** ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេច
- ធ្វើរបាយការណ៍ការងារគ្រប់គ្រងប្រចាំឆ្នាំ ត្រួតពិនិត្យលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យ
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់**ម.ម.ខ.ស.**ក្នុងកម្រិតក្របខណ្ឌចំនួនបុគ្គលិក ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធានការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់ **ម.ម.ខ.ស.**ដែលកំណត់ដោយក្រុមប្រឹក្សាភិបាលស្តីពីការបែងចែកសិទ្ធិអំណាចនិងទៅតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិដទៃទៀត។

**១២.២.** នាយកនៃ **ម.ម.ខ.ស.**ជាតំណាងរបស់មន្ទីរពេទ្យ ក្នុងទំនាក់ទំនងជាមួយតតិយជន។

**១២.៣.** នាយកនៃ **ម.ម.ខ.ស.**ត្រូវស្នើទៅក្រសួងសុខាភិបាល សុំតែងតាំងនាយករងមួយរូប ឬច្រើនរូបដែលជាជំនួយការតាមការចាំបាច់ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល។ នាយក និងនាយករង ត្រូវមានចំណេះដឹងលើផ្នែកគ្រប់គ្រង។

## ផ្នែកទី៣
## បុគ្គលិករបស់ ម.ម.ខ.ស.

**មាត្រា១៣.-**

**១៣.១.** បុគ្គលិកអចិន្ត្រៃយ៍របស់ **ម.ម.ខ.ស.**រួមមានមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈមកពីក្រសួងសុខាភិបាលឬមកពីក្រសួងស្ថាប័នដទៃទៀត។ មន្ត្រីទាំងឡាយនេះត្រូវបានរក្សាទុកក្របខណ្ឌ ប្រាក់បៀវត្ស និង ប្រាក់កម្រៃផ្សេងៗ ដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន។

**១៣.២.** មន្ទីរពេទ្យអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ជំនួយការ និងបុគ្គលិកអណ្តែត។ បុគ្គលិកទាំងនេះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងនិងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ស្តីពីការងារ។

**១៣.៣.** បុគ្គលិក **ម.ម.ខ.ស.**ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីការគ្រប់គ្រង បុគ្គលិកដែលបានសម្រេចដោយក្រុមប្រឹក្សាភិបាល។ ចំពោះមន្ត្រីរាជការនៃមុខងារសាធារណៈ បទបញ្ជាស្តីពីបុគ្គលិកនេះមិនត្រូវផ្ទុយពី

បទប្បញ្ញត្តិទាំងឡាយនៃច្បាប់និងអត្ថបទពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការឡើយ។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កម្រៃលើកទឹកចិត្តចំពោះបុគ្គលិកព្រមទាំងបែបបទនៃការទូទាត់ផង ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង។

## ផ្នែកទី៤
## ទ្រព្យសម្បត្តិនៃមន្ទីរពេទ្យ

**មាត្រា១៤.-**

**១៤.១. ម.ម.ខ.ស.** ទទួលដើមទុនដំបូងពីរដ្ឋជាដីធ្លីនិងអចលនវត្ថុ ដែលមានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធតាមបញ្ជីសារពើភណ្ឌចុងក្រោយ ដែលផ្ទៃដីមានប្រមាណ ១០០ ៥០០ (មួយរយពាន់ប្រាំរយ) ម៉ែត្រក្រឡា ក្នុងនោះមានអាសយដ្ឋាននៅមហាវិថីយោធពលខេមរភូមិន្ទ (ផ្លូវ២៧១) សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**១៤.២. ម.ម.ខ.ស.** អាចទិញ ប្តូរ ឬលក់ចលនទ្រព្យ អចលនទ្រព្យចាំបាច់សម្រាប់ដំណើរការរបស់មន្ទីរពេទ្យដោយមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ និងស្របតាមច្បាប់ជាធរមាន។

## ផ្នែកទី៥
## ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យរបស់ ម.ម.ខ.ស.

**មាត្រា១៥.-**

ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យនៃ **ម.ម.ខ.ស.** ត្រូវប្រព្រឹត្តស្របតាមគោលការណ៍នៃគណនេយ្យសាធារណៈ ដូចមានចែងនៅក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ។

**មាត្រា១៦.-**

**១៦.១.** នាយកនៃ **ម.ម.ខ.ស.** ជាអាណាប័កដើមខ្សែរបស់មន្ទីរពេទ្យហើយត្រូវមានភារកិច្ច÷

- ពិនិត្យប្រាក់និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់និងចេញបញ្ជាចំណាយ។

**១៦.២.** អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាចបង្កើតនូវរជ្ជទេយ្យចំណូលឬបុរេប្រទានបានដោយមានការព្រមព្រៀងពីគណនេយ្យករ **ម.ម.ខ.ស.**។

**មាត្រា១៧.-**

**១៧.១.** ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ **ម.ម.ខ.ស.** ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។ គណនេយ្យករត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ។ គណនេយ្យករនេះត្រូវ

ទទួលខុសត្រូវចំពោះមុខនាយក **ម.ម.ខ.ស.** និងត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់ តែឥតមានសំឡេងឆ្នោតឡើយ ។

**១៧.២.** គណនេយ្យករមានភារកិច្ច ÷

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- ថែរក្សានិងចាត់ចែងប្រើប្រាស់នូវមូលនិធិនិងធនធានរបស់ **ម.ម.ខ.ស.**
- ថែរក្សាលិខិតយុត្តិការនិងកាន់កាប់បញ្ជីគណនេយ្យ ។

**១៧.៣.** គណនេយ្យករអាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុករីរបស់ខ្លួន ។

**មាត្រា១៨.-**

**១៨.១.** ប្រភពធនធានរបស់ **ម.ម.ខ.ស.** រួមមាន ÷

- ធនធានដំបូងរបស់រដ្ឋផ្តល់ដល់ **ម.ម.ខ.ស.** នៅពេលផ្តើមបង្កើតដំបូង
- ឧបត្ថម្ភធនសម្រាប់ដំណើរការនិងឧបត្ថម្ភធនជាមូលធន ដែលមានចែងក្នុងថវិកាជាតិ
- អំណោយ ជំនួយ និងអច្ច័យទានដែល **ម.ម.ខ.ស.** បានទទួល
- ប្រាក់ខ្ចីដោយផ្ទាល់និងប្រាក់ដែលរដ្ឋខ្ចីបុលឱ្យ **ម.ម.ខ.ស.**
- ផលការងារនិងកម្រៃនៃការផ្តល់សេវាផ្សេងៗដោយ **ម.ម.ខ.ស.**
- កម្រៃនៃទ្រព្យរបស់ **ម.ម.ខ.ស.** និងចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល
- កម្រៃនៃទ្រព្យសម្បត្តិដែលបានប្រគល់ឱ្យ **ម.ម.ខ.ស.** ។

**១៨.២.** ចំណូលចំណាយជាប្រចាំព្រមទាំងមូលធនរបស់ **ម.ម.ខ.ស.** ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់ **ម.ម.ខ.ស.** ។ ក្រុមប្រឹក្សាភិបាលរបស់ **ម.ម.ខ.ស.** ត្រូវកំណត់អំពីបែបបទនៃការរៀបចំចាត់ចែង និង អនុវត្តថវិកា។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលទាក់ទងដល់ទម្រង់បែបបទនៃការរៀបចំចាត់ចែង និង អនុវត្តថវិកា ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**១៨.៣.** ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ **ម.ម.ខ.ស.** ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវធ្វើការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្នុងឆ្នាំនីមួយៗ ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹងរវាងចំណូល និង ចំណាយ ។

**១៨.៤.** អនុលោមតាមមាត្រា ១៣ ខាងលើនេះ ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗនៃមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈដែលមកបម្រើការងារក្នុង **ម.ម.ខ.ស.** ជាបន្ទុកនៃថវិការដ្ឋ ។

**១៨.៥.** ប្រាក់ឧបត្ថម្ភរបស់រដ្ឋដែលបានគ្រោងទុកក្នុងថវិកាជាតិ ដើម្បីផ្តល់ឱ្យ **ម.ម.ខ.ស.** ត្រូវសំដៅជាពិសេសលើចំណាយថ្លៃទឹកនិងថ្លៃភ្លើង ។

**១៨.៦.** សោហ៊ុយវិភាគនិងសោហ៊ុយដំណើរការ សម្រាប់ស្រាវជ្រាវវិភាគ សម្រាប់ពេលមានភាពអាសន្ន ត្រូវចែងក្នុងកិច្ចសន្យាមួយរវាងរដ្ឋ និង **ម.ម.ខ.ស.** ដែលមានបញ្ជាក់ចំណែកដែលម្ខាងៗត្រូវរ៉ាប់រង ។

**មាត្រា១៩.-**

**១៩.១.** ការងារគណនេយ្យរបស់ **ម.ម.ខ.ស.** រួមមាន÷

- គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគ ដែលចែងអំពីប្រតិបត្តិការថវិការតនាគារនិង ប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន
- គណនេយ្យ អសង្ហារឹម រូបធាតុ និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគប្រសិនបើជាការចាំបាច់។

គណនេយ្យរបស់ **ម.ម.ខ.ស.** ត្រូវ÷

- ស្របតាមវិធានដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គោរពតាមប្លង់គណនេយ្យរបស់ **ម.ម.ខ.ស.** ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

ប្លង់គណនេយ្យនេះត្រូវបានយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**១៩.២.** របាយការណ៍ស្តីពីការគ្រប់គ្រង និង គណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ **ម.ម.ខ.ស.** ត្រូវរៀបចំដោយ គណនេយ្យករ និង អាណាប័កដើមខ្សែដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣ (បី) ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ។

**មាត្រា២០.-**

មូលនិធិរបស់ **ម.ម.ខ.ស.** គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនីមួយនៅរតនាគារជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិ ដែលត្រូវមានការយល់ព្រមដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៦
## របបសារពើពន្ធនៃ ម.ម.ខ.ស.

**មាត្រា២១.-**

លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់ **ម.ម.ខ.ស.** ត្រូវស្ថិតនៅក្រោមនីតិរួមចំពោះរបបសារពើពន្ធ។

## ផ្នែកទី៧
## លទ្ធកម្មរបស់ ម.ម.ខ.ស.

**មាត្រា២២.-**

ការសម្រេច ការអនុវត្ត និងការត្រួតពិនិត្យលើលទ្ធកម្មរបស់ **ម.ម.ខ.ស.** ត្រូវគ្រប់គ្រងតាមច្បាប់និងបទបញ្ញា ជាធរមានទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហានេះ។

# ជំពូកទី៣

# អាណាព្យាបាលភាព

## ផ្នែកទី១

## អាណាព្យាបាលបច្ចេកទេស

**មាត្រា២៣.-**

**២៣.១** ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាល នាយកនៃ **ម.ម.ខ.ស.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍនិងគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីសុំការយល់ព្រម។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានរយៈពេល ១(មួយ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារ ដើម្បីរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស មានរយៈពេល ២(ពីរ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារ ដែលបានបញ្ជូនដោយនាយកនៃ **ម.ម.ខ.ស.** ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

**២៣.២** លិខិតយល់ព្រមចុះហត្ថលេខា ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាលឬតំណាង ហើយត្រូវផ្ញើជូនទៅនាយកនៃ **ម.ម.ខ.ស.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នាយកនៃ **ម.ម.ខ.ស.** ត្រូវបញ្ជូនព័ត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសុខាភិបាលមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍឬគម្រោងថវិកាប្រចាំឆ្នាំចាត់ទុកថាបានទទួលការឯកភាព។ ប្រសិនបើរដ្ឋមន្ត្រីក្រសួងសុខាភិបាលធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និង រិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ។

កម្មវិធីអភិវឌ្ឍនៃ **ម.ម.ខ.ស.** និងថវិកាចំណាយជាមូលធនមិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាលពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ។

ថវិកាចំណាយជាប្រចាំអាចដាក់ឱ្យអនុវត្តត្រឹមលំនាំប្រព័ន្ធបំបែកជា ១២(ដប់ពីរ)ប៉ុណ្ណោះ នៅពេលដែលមានការជំទាស់ពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា២៤.-**

**២៤.១** រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាចមានយោបល់ជំទាស់លើឯកសារ ដែលត្រូវបានបញ្ជូនមកខ្លួនដូចមានចែងក្នុងមាត្រា ១០ ចំណុច ១០.៤ នៃអនុក្រឹត្យនេះ មានកំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍ស្តីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានរយៈពេល ១(មួយ)ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងអស់នេះ។

**២៤.២** នាយកនៃ **ម.ម.ខ.ស.** ត្រូវជូនព័ត៌មានទៅដល់ក្រុមប្រឹក្សាភិបាល អំពីខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាឱ្យបានឆាប់បំផុតលើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់នេះ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចពុំ

យកជាបានការនូវការជំទាស់ទាំងនេះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជម្រាបជាបន្ទាន់ភ្លាមនូវដំណឹងអំពីបញ្ហានេះជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា២៥.-**

**២៥.១** រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចលុបឬផ្អាកទុកនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ **ម.ម.ខ.ស.** ក្នុងករណីដែលសេចក្តីសម្រេចនោះ÷

- ផ្ទុយនឹងគោលដៅរបស់មន្ទីរពេទ្យ
- ផ្ទុយនឹងច្បាប់និងបទបញ្ជា
- ធ្វើឡើងដោយអាជ្ញាធរមួយដែលពុំមានសិទ្ធិសម្រេច ឬធ្វើឡើងដោយការប្រជុំពុំស្របច្បាប់របស់ក្រុមប្រឹក្សាភិបាល។

**២៥.២** ការលុបចោលឬការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ។ ការលុបចោលឬផ្អាកទុកនូវសេចក្តីសម្រេចនេះ ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរដល់នាយកនៃ **ម.ម.ខ.ស.** ហើយនាយក **ម.ម.ខ.ស.**ត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាលក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា២៦.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចចាត់ឱ្យធ្វើអធិការកិច្ចឬការត្រួតពិនិត្យការងាររបស់ **ម.ម.ខ.ស.** ក្នុងករណីដែលយល់ថាជាការចាំបាច់ស្របតាមលក្ខខណ្ឌនិងបែបបទដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី២
## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា២៧.-**

**២៧.១** ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល នាយកនៃ **ម.ម.ខ.ស.**ត្រូវផ្ញើរបាយការណ៍ស្តីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។ រដ្ឋមន្ត្រីក្រសួងសុខាភិបាល មានរយៈពេល ១(មួយ)ខែ គិតចាប់ពីថ្ងៃទទួលឯកសារ ដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានរយៈពេល ២(ពីរ)ខែ គិតចាប់ពីថ្ងៃទទួលឯកសារដែលបញ្ជូនមក ដោយនាយកនៃ **ម.ម.ខ.ស.**ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

**២៧.២** លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬអ្នកតំណាងត្រូវផ្ញើទៅនាយកនៃ **ម.ម.ខ.ស.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល។ នាយកនៃ **ម.ម.ខ.ស.**ត្រូវជូនព័ត៌មាននេះដល់ក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនបានឆ្លើយតប ក្នុងរយៈពេលដូចបានកំណត់ខាងលើរបាយការណ៍ស្តីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព។ ក្នុងករណីដែល

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុត ដើម្បីរិះរកមធ្យោបាយដោះស្រាយជំទាស់ទាំងនេះ។ របាយការណ៍ស្ដីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំមិនអាចត្រូវសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពុំត្រូវបានដោះស្រាយនៅឡើយនោះ។

**មាត្រា២៨.-**

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលឬនាយកនៃ **ម.ម.ខ.ស.** ត្រូវដាក់សុំការអនុញ្ញាតជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមការផ្ដល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន ÷

- សេចក្ដីសម្រេចស្ដីពីការលើកលែងគណនេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សេចក្ដីសម្រេចស្ដីពីកិច្ចព្រមព្រៀងខ្ចីប្រាក់និងកិច្ចព្រមព្រៀងសម្រាប់ការធានាឬលិខិតស្រដៀងគ្នានេះ
- សេចក្ដីសម្រេចស្ដីពីការលក់ឬផ្ទេរសិទ្ធិអចលនទ្រព្យ។

សេចក្ដីសម្រេចនេះត្រូវអនុលោមតាមនីតិវិធីច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា២៩.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ១(មួយ)រូបប្រចាំ **ម.ម.ខ.ស.** មន្ត្រីនេះមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុននិងជាក្រោយលើ **ម.ម.ខ.ស.** ស្របតាមអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាតាមក្រសួង ខេត្តក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងតាមអង្គភាពសាធារណរដ្ឋបាល។

**មាត្រា៣០.-**

៣០.១ ការគ្រប់គ្រងដោយអាណាប័កដើមខ្សែនៃ **ម.ម.ខ.ស.** ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣០.២ ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់គណនេយ្យករកណ្ដាលនៃរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣០.៣. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់អធិការកិច្ច ឬ ការត្រួតពិនិត្យលើ **ម.ម.ខ.ស.** នៅពេលដែលយល់ថាចាំបាច់ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា៣១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមិថុនា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ដើម្បីសូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកកងមាស នៃខេត្តកំពង់ចាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ១៣៧ គជប.សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីបេក្ខជនជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកកងមាស នៃខេត្តកំពង់ចាម អាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

១- លោក **ម៉ក់ លីមអ៊ន់** ជាប្រធានក្រុមប្រឹក្សាស្រុក

២- លោក ឈឺន ឈាងហួ ជាសមាជិកក្រុមប្រឹក្សាស្រុក

៣- លោក ម៉ាត់ ស៊ីផុន ជាសមាជិកក្រុមប្រឹក្សាស្រុក

៤- លោក ម៉ុក ស៊ឹម ជាសមាជិកក្រុមប្រឹក្សាស្រុក

៥- លោក ពិន ស៊ឹមអេង ជាសមាជិកក្រុមប្រឹក្សាស្រុក

៦- លោក អ៊ុំ ទាវ៉ន់ថា ជាសមាជិកក្រុមប្រឹក្សាស្រុក

៧- លោកស្រី ណុប ស៊ីដេត ជាសមាជិកក្រុមប្រឹក្សាស្រុក

៨- លោក គី ទ្វ៉ង ជាសមាជិកក្រុមប្រឹក្សាស្រុក

៩- លោកស្រី ហ៊ាន់ ទ្រពៀ ជាសមាជិកក្រុមប្រឹក្សាស្រុក

១០- លោក យ៉ាន់ រុន ជាសមាជិកក្រុមប្រឹក្សាស្រុក

១១- លោក ខឹន អ៊ី ជាសមាជិកក្រុមប្រឹក្សាស្រុក

១២- លោក អេន ណារិទ្ធិ ជាសមាជិកក្រុមប្រឹក្សាស្រុក

១៣- លោក ម៉ែន សុភអេង ជាសមាជិកក្រុមប្រឹក្សាស្រុក

១៤- លោក អោម តំស្លា ជាសមាជិកក្រុមប្រឹក្សាស្រុក

១៥- លោក លន់ សុខថៃ ជាសមាជិកក្រុមប្រឹក្សាស្រុក

១៦- លោក គង់ សាវ័ន ជាសមាជិកក្រុមប្រឹក្សាស្រុក

១៧- លោកស្រី ម៉ិច សុវណ្ណា ជាសមាជិកក្រុមប្រឹក្សាស្រុក

១៨- លោកស្រី ហន រ៉ាវី ជាសមាជិកក្រុមប្រឹក្សាស្រុក

១៩- លោកស្រី យ៉ាន សោភា ជាសមាជិកក្រុមប្រឹក្សាស្រុក ។

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់ បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា២៣ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកកងមាស នៃខេត្តកំពង់ចាម ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩*

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
  *(ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...៤.៧៣..អនក្រ.តត**

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកកោះសូទិន នៃខេត្តកំពង់ចាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ '១៣៧ គជប.សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីបេក្ខជនជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកកោះសូទិន នៃខេត្តកំពង់ចាម អាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

១- លោក **អ៊ុន មេងស៊ន់** ជាប្រធានក្រុមប្រឹក្សាស្រុក

២- លោក **ហេង ហ៊ុន** ជាសមាជិកក្រុមប្រឹក្សាស្រុក
៣- លោក **ពេញ ហាន** ជាសមាជិកក្រុមប្រឹក្សាស្រុក
៤- លោក **ឈឹម ជា** ជាសមាជិកក្រុមប្រឹក្សាស្រុក
៥- លោក **និត ហេង** ជាសមាជិកក្រុមប្រឹក្សាស្រុក
៦- លោកស្រី **តួច សុខជា** ជាសមាជិកក្រុមប្រឹក្សាស្រុក
៧- លោក **ចក់ ទើង** ជាសមាជិកក្រុមប្រឹក្សាស្រុក
៨- លោកស្រី **មាស សុខនៅ** ជាសមាជិកក្រុមប្រឹក្សាស្រុក
៩- លោក **ឆ័ន់ ម៉េង** ជាសមាជិកក្រុមប្រឹក្សាស្រុក
១០- លោក **ចាន់ គិមជិន** ជាសមាជិកក្រុមប្រឹក្សាស្រុក
១១- លោក **សួយ ណារីន** ជាសមាជិកក្រុមប្រឹក្សាស្រុក
១២- លោក **សេក សណ្ដាប់** ជាសមាជិកក្រុមប្រឹក្សាស្រុក
១៣- លោក **ម៉ិច សុខហេង** ជាសមាជិកក្រុមប្រឹក្សាស្រុក
១៤- លោក **ឌន់ ធឿន** ជាសមាជិកក្រុមប្រឹក្សាស្រុក
១៥- លោក **គង់ ជ័យ** ជាសមាជិកក្រុមប្រឹក្សាស្រុក
១៦- លោក **សំ ឃួន** ជាសមាជិកក្រុមប្រឹក្សាស្រុក
១៧- លោក **ម៉ៅ ម៉េងអាន** ជាសមាជិកក្រុមប្រឹក្សាស្រុក ។

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់ បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា២៣ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកកោះសូទិន នៃខេត្តកំពង់ចាម ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០០៩*

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
  *(ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកក្រូចឆ្មារ នៃខេត្តកំពង់ចាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ១៣៧ គជប.សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីបេក្ខជនជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកក្រូចឆ្មារ នៃខេត្តកំពង់ចាម អាណត្តិទី១ ដូចមានរាយនាមខាងក្រោម ៖

១- លោក **ស៊ាក ឡេង** ជាប្រធានក្រុមប្រឹក្សាស្រុក

២- លោក អ៊ុច អ៊ន ជាសមាជិកក្រុមប្រឹក្សាស្រុក
៣- លោក ស្រ៊ុន ស៊ីចន ជាសមាជិកក្រុមប្រឹក្សាស្រុក
៤- លោក ទូលាស់ ម៉ាត់ ជាសមាជិកក្រុមប្រឹក្សាស្រុក
៥- លោក ធី ចន់ ជាសមាជិកក្រុមប្រឹក្សាស្រុក
៦- លោកស្រី ភង ស៊ីម្មនី ជាសមាជិកក្រុមប្រឹក្សាស្រុក
៧- លោក ហាម ឈាង ជាសមាជិកក្រុមប្រឹក្សាស្រុក
៨- លោក ថោង សៀង ជាសមាជិកក្រុមប្រឹក្សាស្រុក
៩- លោកស្រី គុត ស៊ីម ជាសមាជិកក្រុមប្រឹក្សាស្រុក
១០- លោក មល់ ផេង ជាសមាជិកក្រុមប្រឹក្សាស្រុក
១១- លោក ឈៀង ចាន់សេង ជាសមាជិកក្រុមប្រឹក្សាស្រុក
១២- លោក យង់ យាន ជាសមាជិកក្រុមប្រឹក្សាស្រុក
១៣- លោក ឡោ ហុងសេង ជាសមាជិកក្រុមប្រឹក្សាស្រុក
១៤- លោក ម៉ៅ ឈាងហ៊ីរ ជាសមាជិកក្រុមប្រឹក្សាស្រុក
១៥- លោក ម៉ៅ ចិន្តាមុនី ជាសមាជិកក្រុមប្រឹក្សាស្រុក
១៦- លោក យូ យ៉ឹង ជាសមាជិកក្រុមប្រឹក្សាស្រុក
១៧- លោក គីម ទេងស៊ាង ជាសមាជិកក្រុមប្រឹក្សាស្រុក
១៨- លោក ជ្រិន ម៉ារ៉ែត ជាសមាជិកក្រុមប្រឹក្សាស្រុក
១៩- លោក អ៊ិន ស៊ីម ជាសមាជិកក្រុមប្រឹក្សាស្រុក ។

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់ បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកក្រូចឆ្មារ នៃខេត្តកំពង់ចាម ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*

*(ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកមេមត់ នៃខេត្តកំពង់ចាម

## រាជរដ្ឋាភិបាល

